ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ
សាលក្រម
លេខ ០៥ (ខ) ចុះថ្ងៃទី ០៨
ខែ កុម្ភៈ ឆ្នាំ ២០០៦
សំណុំរឿងរដ្ឋប្បវេណី
លេខ ៤១ ចុះថ្ងៃទី ០៦
ខែ កុម្ភៈ ឆ្នាំ ២០០៦

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្ត

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ៤១ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដែលមានកម្មវត្ថុបណ្តឹង

-ប្តឹងសុំលែងលះប្តី ។

រវាងដើមចោទឈ្មោះ ល មស អាយុ ២៧ឆ្នាំ ជាតិខ្មែរ របររកស៊ីសំអាងការ ទីលំនៅសព្វថ្ងៃនៅភូមិកំពង់ថ្កូវ ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ឪពុកឈ្មោះ លីទ (ស) ម្តាយឈ្មោះ ស ឡ (រ) ប្តីឈ្មោះ ឌ ម គ្មានកូន ។

និង ចុងចម្លើយឈ្មោះ ឌ ម អាយុ ៥៦ឆ្នាំ ជាតិខ្មែរ របររកស៊ី មន្ត្រីពន្ធដាស្រុកក្រឡាញ់ ទីលំនៅសព្វថ្ងៃនៅភូមិកំពង់ថ្កូវ ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ឪពុកឈ្មោះ ឧ ឌ (ស) ម្តាយឈ្មោះ ឧ ព (ស) ប្រពន្ធឈ្មោះ ល មស គ្មានកូន ។

**ងរឿងហេតុមានដូចតទៅ :**

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ ល សម បានប្តឹងថា ខ្លួនប្តឹងសុំលែងលះឈ្មោះ ឌ ម ដោយសំអាងហេតុថា កាលពីឆ្នាំ ១៩៩៦ ខ្លួន និង ឈ្មោះ ឌ ម បានគ្នាជាប្តីប្រពន្ធតាមច្បាប់ ប៉ុន្តែពុំមានកូនទេ ។ ការរស់នៅជាប្តីប្រពន្ធមិនចុះសំរុងគ្នា ពីព្រោះប្តីខ្លួនមានកូនដើមរបស់គាត់ ហើយជឿតែសំដីរបស់កូន មិនគិតពីអនាគតខ្លួនជាប្រពន្ធទេ ។ ម្យ៉ាងទៀតប្តីខ្លួនតែងតែប្រច័ណ្ឌខ្លួនទៅនឹងអ្នកដទៃ ទើបបណ្តាលអោយខ្លួនអស់មនោសញ្ចេតនានឹងគ្នា ។

*សាលក្រមនេះចូលជាស្ថាពរ ចាប់ពីថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦*
*ដោយពុំមានភាគីណាចូលមកប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*
*សៀមរាប. ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦*
*ក្រឡាបញ្ជី*
*ហត្ថលេខា និង ត្រា*
[redacted]

## នារពលសទនាគារ

ដេិមចោទឈ្មោះ ល សម បានរៀបថា ខ្លួនប្តឹងសុំលែងលះប្តីឈ្មោះ ឌ ម ដោយសំអាងហេតុថា កាលពីឆ្នាំ ១៩៨៦ ខ្លួន និងឈ្មោះ ឌ ម បានគ្នាជាប្តីប្រពន្ធតាមច្បាប់ ប៉ុន្តែពុំមានកូនទេ ។ ការរស់នៅជាប្តីប្រពន្ធ មិនចុះសំរុងគ្នា ពីព្រោះប្តីខ្លួនមានកូនដេីមរបស់គាត់ ហេីយជឿតែសំដីរបស់កូន មិនគិតគូរពីអនាគតខ្លួនជាប្រពន្ធទេ។ ម្យ៉ាងទៀតប្តីខ្លួនតែងតែប្រច័ណ្ឌខ្លួនទៅនឹងអ្នកដទៃ ទើបបណ្តាលអោយខ្លួនអស់មនោសញ្ចេតនាពីគ្នា ។ ចំពោះទ្រព្យសម្បត្តិរួមមានរថយន្ត ០១គ្រឿង ម៉ាក CAMARY ស៊េរីឆ្នាំ ១៩៩៥ ចង្កូតស្តាំ ពណ៌ទឹកប្រាក់ និង ដីមួយប្លង់ ទំហំ ៤ម×៨ម មានផ្ទះថ្មស្ថិតនៅក្នុងភូមិកំពង់ថ្កូវ ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។ ចំពោះទ្រព្យសម្បត្តិរួមនេះ ខ្លួនសុំសិទ្ធិគ្រប់គ្រងរថយន្ត និង សុំអោយប្តីឧបត្ថម្ភជាប្រាក់ចំនួន ២.០០០ដុល្លាមកខ្លួន ។ ចំណែកដី និង ផ្ទះ ខ្លួនប្រគល់អោយប្តីគ្រប់គ្រងជាកម្មសិទ្ធិ ។ ចំពោះបំណុលរួមគ្មានទេ ។

ចុងចម្លើយឈ្មោះ ឌ ម បានឆ្លើយថា ខ្លួនយល់ព្រមលែងលះប្រពន្ធខ្លួន ដោយមូលហេតុថា ការរស់នៅមិនចុះសំរុងគ្នាមែន ប្រពន្ធខ្លួនទៅណាមកណាមិនដែលប្រាប់ខ្លួនជាប្តី និង ម្យ៉ាងទៀតខ្លួន និង ប្រពន្ធបានគ្នាពុំមានកូន ។ ចំពោះទ្រព្យសម្បត្តិរួមមានដូចដេីមចោទជាប្រពន្ធលើកឡើងមែន ដោយខ្លួនសុខចិត្តប្រគល់រថយន្តទៅដេីមចោទគ្រប់គ្រងជាកម្មសិទ្ធិ ។ ចំណែកខ្លួនសុំសិទ្ធិគ្រប់គ្រងនូវដី និង ផ្ទះ ហើយខ្លួនប្រគល់ប្រាក់ចំនួន ២.០០០ដុល្លា (ពីរពាន់ដុល្លា) ទៅដេីមចោទ ។ ចំពោះបំណុលរួមគ្មានទេ ។

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមសវនាការនេះ គោលដៅអាពាហ៍ពិពាហ៍លែងបានសំរេចស្ថានភាពប្តីប្រពន្ធមានភាពធ្ងន់ធ្ងរ ភាគីទាំងពីរពុំអាចរួមរស់នៅជាមួយគ្នាតទៅទៀតបានឡើយ ដោយដេីមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នា ។

ហេតុនេះសុំតុលាការពិចារណាសំរេចតាមច្បាប់ចុះ ។

-បានស្តាប់ដេីមចោទឆ្លើយអោយការណ៍ និងប្តឹងសុំ

-បានស្តាប់សេចក្តីដោះសាររបស់ចុងចម្លើយ

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-ពាក្យបណ្តឹងរបស់ដេីមចោទចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-គូស្វាមីភរិយានេះ បានគ្នាជាប្តីប្រពន្ធ មានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

-ដេីមចោទ ប្តឹងសុំលែងលះចុងចម្លើយ ហើយចុងចម្លើយបានព្រមព្រៀងដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ទ្រព្យសម្បត្តិរួម ដេីមចោទសុំសិទ្ធិគ្រប់គ្រងរថយន្ត ០១គ្រឿង ម៉ាក CAMARY ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ ១៩៩៥ និងទាមទារប្រាក់ចំនួន ២.០០០ដុល្លា ហើយសុខចិត្តប្រគល់ដី ១ប្លង់ទំហំ ៤ម x ៨ម ស្ថិតនៅភូមិកំពង់ថ្កូវ ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ទៅចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិ ចុងចម្លើយ

ព្រមព្រៀងដែរនោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-បំណុលរួមពុំមានទេនោះ តុលាការពុំបានពិចារណាអំពីបញ្ហានេះឡើយ ។

-គោលដៅនៃអាពាហ៍ពិពាហ៍ពុំអាចសំរេចបានឡើយ ដោយដើមចោទ និង ចុងចម្លើយអស់មនោសញ្ចេតនាពីគ្នា ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចអោយឈ្មោះ **ល សម** និង ឈ្មោះ **ឌ ម** លែងលះគ្នាចាប់ពីថ្ងៃនេះតទៅ តាមការព្រមព្រៀងរបស់គូភាគី ដាក់កំហុសលើប្តី ។

៣-អោយឈ្មោះ **ល សម** ស្ថិតនៅភាពមេម៉ាយចំនួន ៣០០ថ្ងៃគិតចាប់ពីថ្ងៃនេះតទៅ ។

៤-ទ្រព្យសម្បត្តិរួម រថយន្ត ០១គ្រឿង ម៉ាក CAMARY ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ ១៩៩៥ ត្រូវប្រគល់អោយឈ្មោះ **ល សម** គ្រប់គ្រងជាកម្មសិទ្ធិ ។ ចំណែកដីមួយប្លង់ទំហំ ៤ម x ៨ម ស្ថិតនៅភូមិកំពង់ថ្កូវ ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ត្រូវប្រគល់អោយឈ្មោះ **ឌ ម** គ្រប់គ្រងជាកម្មសិទ្ធិ តែអោយឈ្មោះ **ឌ ម** ឧបត្ថម្ភប្រាក់ចំនួន ២.០០០ដុល្លា ( ពីរពាន់ដុល្លា) ទៅឈ្មោះ **ល សម** តាមការព្រមព្រៀងរបស់គូភាគី ។

៥-សំរេចអោយចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ១.៨០០រ៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០រ៛០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រ៛០០ បូករួម ៧.០០០រ៛០០ ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ៛០០ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់អោយចុងចម្លើយសងប្រាក់ ៧.០០០រ៛០០ នេះទៅដើមចោទវិញ ។

៦-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូភាគី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ០២ខែគិតពីថ្ងៃនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជំរះ**

[redacted] | [redacted]